ascia
australasian society of clinical immunology and allergy
www.allergy.org.au

Information
FOR PATIENTS, CONSUMERS AND CARERS

ព័ត៌មានជាសាធារៈអំពីប្រតិកម្មអាណាហ្វីឡាក់ស៊ីស (Anaphylaxis) សំរាប់ឪពុកម្តាយ ដែលមានកូនរងគ្រោះដោយប្រតិកម្មអាណាហ្វីឡាក់ស៊ីស

តើអ្វីទៅជាប្រតិកម្មអាណាហ្វីឡាក់ស៊ីស ហើយតើគេត្រូវព្យាបាលដោយរបៀបណា?

ប្រតិកម្មអាណាហ្វីឡាក់ស៊ីស គឺជាប្រភេទធ្ងន់ធ្ងរបំផុតនៃប្រតិកម្មអាល្លើជី ហើយអាចប៉ះពាល់ដល់អាយុជីវិត។ ជាធម្មតាវាកើតឡើងភ្លាមៗ បន្ទាប់ពីការប្រទះជាមួយចំណីអាហារ សត្វល្អិត ឬឱសថ ដែលអ្នកជំងឺអាចមានប្រតិកម្មជាមួយរួចមកហើយ។ ប្រតិកម្មអាណាហ្វីឡាក់ស៊ីស ត្រូវតែព្យាបាលក្នុងលក្ខណៈបន្ទាន់ជានិច្ច ហើយតម្រូវឱ្យមានការព្យាបាលភ្លាមៗជាមួយអាដ្រេណាលីន (adrenaline) (អេភីណេហ្វ្រីន) (epinephrine)។ **ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិ**ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជូនដោយបុគ្គលដែលគ្មានជំនាញវេជ្ជសាស្ត្រ ដូចជាឪពុកម្តាយ បុគ្គលិកសាលារៀន ឬអ្នកថែទាំកុមារ មិត្តភក្តិ អ្នកដទៃផ្សេងៗទៀត ឬពីសំណាក់អ្នកជំងឺខ្លួនឯងផ្ទាល់ (ប្រសិនបើគេមានសុខភាពល្អ ហើយចាស់គ្រប់គ្រាន់)។ ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិមានផ្ទុកអាដ្រេណាលីន ដែលមានកំរិតតែមួយជាក់លាក់ ដែលធ្វើការយ៉ាងលឿនឱ្យប្រតិកម្មអាណាហ្វីឡាក់ស៊ីសត្រឡប់ក្រោយភ្លាមៗ។ សេចក្តីណែនាំត្រូវបានរួមបញ្ចូលនៅក្នុងស្លាកនៃឧបករណ៍នោះ ក្នុងផែនការសកម្មភាព ASCIA សំរាប់ប្រតិកម្មអាណាហ្វីឡាក់ស៊ីស និងគេហទំព័រនៃ ASCIA: www.allergy.org.au/anaphylaxis

ប្រសិនបើកូនរបស់លោកអ្នកត្រូវបានធ្វើរោគវិនិច្ឆ័យថា អាចទទួលរងប្រតិកម្មអាណាហ្វីឡាក់ស៊ីស នោះគ្រូពេទ្យព្យាបាលគួរតែផ្តល់៖

☐ **ការអប់រំអំពីការចៀសវាងសារជាតិដែលធ្វើឱ្យមានប្រតិកម្មអាល្លើជី។** វាមានសារៈសំខាន់ណាស់ជាមួយប្រតិកម្មអាណាហ្វីឡាក់ស៊ីស ដោយសារប្រតិកម្មអាល្លើជីជាមួយចំណីអាហារ ដែលអាចបង្កឡើងដោយបរិមាណតិចតួចនៃចំណីអាហារ ឬការប្រទះជាមួយអ្វីមួយដោយចៃដន្យ។ យុទ្ធសាស្ត្រ ដើម្បីចៀសវាងការប្រទះជាមួយចំណីអាហារ និងសារជាតិដែលធ្វើឱ្យមានប្រតិកម្មជាមួយសត្វល្អិតនោះ គួរតែត្រូវបានអនុវត្តនៅផ្ទះ និងសាលារៀន ឬសាលាមត្តេយ្យ ឬទារកដ្ឋាន។
ព័ត៌មានបន្ថែមអាចស្វែងរកបានលើគេហទំព័រ ASCIA: www.allergy.org.au/schools-childcare
គេហទំព័រអំពីប្រតិកម្មអាល្លើជីជាមួយចំណីអាហារ - www.allergy.org.au/patients/food-allergy
គេហទំព័រអំពីប្រតិកម្មអាល្លើជីជាមួយសត្វល្អិត - www.allergy.org.au/patients/insect-allergy-bites-and-stings

☐ **ផែនការសកម្មភាព ASCIA សំរាប់ប្រតិកម្មអាណាហ្វីឡាក់ស៊ីស។** ផែនការនេះរៀបរាប់នូវអ្វីដែលត្រូវធ្វើ ប្រសិនបើកូនរបស់លោកអ្នកមានប្រតិកម្មអាល្លើជី។ ឯកសារនេះត្រូវបំពេញ និងចុះហត្ថលេខាដោយគ្រូពេទ្យរបស់កូនលោកអ្នក ហើយរក្សាទុកជាមួយប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិ បើទោះបីកុមារត្រូវកាន់វាតាមខ្លួនក៏ដោយ។ ផែនការនោះរួមបញ្ចូលនូវព័ត៌មានផ្ទាល់ខ្លួន សញ្ញានៃប្រតិកម្មអាល្លើជី សេចក្តីណែនាំអំពីរបៀបប្រើប្រាស់ឧបករណ៍ និងអំពីឱសថផ្សេងៗទៀត ដែលត្រូវផ្តល់ជូន។

☐ **វេជ្ជបញ្ជាសំរាប់ទទួលបានប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិពីរគ្រឿង។** នេះ គឺដើម្បីអនុញ្ញាតឱ្យលោកអ្នករក្សាប្រដាប់មួយគ្រឿងជាមួយកូនរបស់លោកអ្នកគ្រប់ពេលវេលា (ទោះបីនៅក្នុងឬនៅក្រៅផ្ទះក្តី) ហើយប្រដាប់មួយគ្រឿងទៀតយកទៅសាលារៀន ឬទារកដ្ឋាន។ សិស្សនៅវិទ្យាល័យ និងអនុវិទ្យាល័យគួរតែដាក់ប្រដាប់នោះតាមខ្លួនជាធម្មតា ហើយមួយទៀតរក្សាទុកនៅសាលារៀន។ ឧបករណ៍ពីរគ្រឿងត្រូវបាន PBS ជួយបង់ថ្លៃពេញនៅប្រទេសអូស្ត្រាលី ហើយឧបករណ៍ថែមទៀតគេអាច ទិញក្នុងតម្លៃពេញពីឱសថស្ថានបាន។ សំរាប់ព័ត៌មានបន្ថែម:
www.allergy.org.au/health-professionals/anaphylaxis-resources/adrenaline-autoinjectors-faqs

☐ **ការអប់រំអំពីរបៀបប្រើប្រាស់ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិ។** លោកអ្នកត្រូវបានស្នើឱ្យធ្វើការហាត់សមប្រើ ជារឿយៗ ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិប្រភេទសម្រាប់អ្នកបណ្តុះបណ្តាល ដែលត្រូវបានផ្តល់ក្នុងវេជ្ជបញ្ជាសំរាប់កូនរបស់លោកអ្នក។ ប្រភេទសម្រាប់អ្នកបណ្តុះបណ្តាលនៃឧបករណ៍នោះ គ្មានម្ជុលទេ ហើយក៏គ្មានសារជាតិអាដ្រេណាលីនដែរ ដូច្នេះគេអាចបានប្រើច្រើនដងបាន ដើម្បីការហាត់សម និងបង្រៀនដល់ក្រុមគ្រួសារ និងមិត្តភក្តិ។

☐ **ព័ត៌មានអំពីសញ្ញាសំគាល់បែបវេជ្ជសាស្ត្រនៅលើគ្រឿងអលង្កា។** នេះមានលក្ខណៈឥតបង្ខំ ហើយមិនជំនួស ផែនការសកម្មភាព ASCIA សំរាប់ប្រតិកម្មអាណាហ្វីឡាក់ស៊ីសឡើយ។

តើតួនាទីរបស់ឪពុកម្តាយគឺមានអ្វីខ្លះ?

☐ **ជូនដំណឹងដល់នាយកសាលា ឬអ្នកគ្រប់គ្រងនៅសាលាមត្តេយ្យ និងទារកដ្ឋាន** ប្រសិនបើកូនរបស់លោកអ្នកត្រូវបានចេញវេជ្ជបញ្ជាឱ្យប្រើប្រាស់ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិ ឬប្រសិនបើមានប្រតិកម្មអាណាហ្វីឡាក់ស៊ីសពីមុនមក ឬជាបន្តបន្ទាប់ ឬប្រតិកម្មអាល្លើជីមានការផ្លាស់ប្តូរ ហើយនិងបើមានតម្រូវការថែទាំផ្នែកសុខភាពផ្សេងៗទៀត ឬមានពិការភាព (ដោយរួមទាំងការពិបាករៀនសូត្រ) ដែលអាចប៉ះពាល់ដល់ការគ្រប់គ្រងលើប្រតិកម្មអាណាហ្វីឡាក់ស៊ីសនោះ។

☐ **ផ្តល់ផែនការសកម្មភាព ASCIA សំរាប់ប្រតិកម្មអាណាហ្វីឡាក់ស៊ីស ដែលបានបំពេញ និងចុះហត្ថលេខាដោយគ្រូពេទ្យរបស់កូនលោកអ្នក។ ឯកសារនេះ**គួរតែរក្សាឱ្យមានបច្ចុប្បន្នភាព (រួមទាំងរូបថត) នៅពេលណាមានវេជ្ជបញ្ជាឱ្យប្រើប្រាស់ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិសាជាថ្មី (ជាធម្មតារៀងរាល់ ១២ ទៅ ១៨ខែម្តង) ឬប្រសិនបើប្រតិកម្មអាល្លើជីមានការផ្លាស់ប្តូរ។ ផែនការទាំងនេះ គឺជាឯកសារវេជ្ជសាស្ត្រ ហើយមិនត្រូវបំពេញ ឬកែដោយឪពុកម្តាយ បុគ្គលិកនៅសាលារៀន ឬបុគ្គលនៅទារកដ្ឋានឡើយ។

☐ **ផ្តល់ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិទៅឱ្យសាលារៀន សាលាមត្តេយ្យ ឬទារកដ្ឋានរបស់កូនលោកអ្នក។** ចូរកត់សំគាល់អំពីកាលបរិច្ឆេទជានិច្ចនៅលើស្លាក ហើយផ្លាស់ប្តូរឧបករណ៍មុនពេលវាផុតកាលកំណត់។ បើទោះបីកូនរបស់លោកអ្នកកាន់តាមខ្លួននូវប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិក៏ដោយ អ្នកគួរតែផ្តល់ប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិមួយទៀតឱ្យទៅសាលារៀន។ ការធ្វើដូច្នេះ គឺជាការតម្រូវសំរាប់ករណីខ្លះ ដែលកូនរបស់អ្នកភ្លេចដាក់ជាប់តាមខ្លួន នៅពេលកូនលោកអ្នកត្រូវការ។

☐ **ជួយបង្កើតផែនការថែទាំសុខភាពបុគ្គល ឬផែនការកាត់បន្ថយហានិភ័យ។** នេះគឺជាផែនការដែលបុគ្គលិកនៃសាលារៀន សាលាមត្តេយ្យ ឬទារកដ្ឋានបង្កើត ដើម្បីជួយជ្រោមជ្រែងតម្រូវការថែទាំសុខភាពរបស់កូនលោកអ្នក។

☐ **ការអប់រំតាមអាយុ ។** ចូរអប់រំកូនរបស់លោកអ្នកអំពីរបៀបចៀសវាងសារជាតិដែលធ្វើឱ្យមានប្រតិកម្ម និងហេតុអ្វីបានជាវាមានសារៈសំខាន់។ ចូររំលឹកកូនថា ប្រសិនបើគេមានអារម្មណ៍ថាឈឺ គេគួរតែប្រាប់នរណាម្នាក់នៅជិតនោះភ្លាមៗ ដូចជាគ្រូបង្រៀន ឬមនុស្សពេញវ័យណាផ្សេងទៀត។ ចូរបញ្ជាក់ឱ្យប្រាកដដល់គេថា ជារឿងត្រឹមត្រូវ ដែលធ្វើដូច្នោះ ហើយគេមិនគួរភ័យខ្លាចចំពោះការមានបញ្ហាដោយសារការសុំជំនួយដូច្នោះឡើយ។

តើទំនួលខុសត្រូវរបស់សាលារៀន សាលាមត្តេយ្យ ឬទារកដ្ឋានរបស់កូនលោកអ្នកមានអ្វីខ្លះ?

☐ **បណ្តុះបណ្តាលបុគ្គលិក**ឱ្យមានការយល់ដឹង ការគ្រប់គ្រង ការសំគាល់ និងការព្យាបាលបន្ទាន់សំរាប់ប្រតិកម្មអាណាហ្វីឡាក់ស៊ីស។

☐ **ការអនុវត្តយុទ្ធសាស្ត្រ** ដើម្បីកាត់បន្ថយហានិភ័យនៃការប្រទះដោយចៃដន្យ និងសារជាតិដែលធ្វើឱ្យមានប្រតិកម្ម ដោយរួមទាំងព្រឹត្តការណ៍ពិសេសៗ ដូចជាដំណើរកំសាន្តជាក្រុមជាដើម។

☐ **ការរក្សាទុកត្រឹមត្រូវនៃប្រដាប់ចាក់អាដ្រេណាលីនស្វ័យប្រវត្តិ**ជាមួយផែនការសកម្មភាព ASCIA សំរាប់ប្រតិកម្មអាណាហ្វីឡាក់ស៊ីសនៅទីតាំងដែលអាចយកបានស្រួលផុតពីពន្លឺថ្ងៃ និងកំដៅ។ បុគ្គលិកក៏ត្រូវដឹងផងដែរនូវទីតាំងដែលបានព្រមព្រៀងគ្នាទុក ឧបករណ៍ដែលសិស្សយកតាមខ្លួន (ដូចជាហោប៉ៅ កាបូបស្ពាយ កាបូបសៀវភៅជាដើម)។

ព័ត៌មានបន្ថែម

☐ Australasian Society of Clinical Immunology and Allergy (វិសាលភាពសង្គមអូស្ត្រាលីនៃផ្នែកបង្កើតភាពស៊ាំ និងប្រតិកម្មអាល្លើជី) **(ASCIA)** **www.allergy.org.au**
អង្គភាពផ្នែកវេជ្ជសាស្ត្រអាជីព ដែលផ្តល់ការបណ្តុះបណ្តាលតាមប្រព័ន្ធអ៊ីនធើណិត ធនធានបែបអាជីពនៃសុខភាព ព័ត៌មានសំរាប់អ្នកជំងឺ និងអ្នកប្រើប្រាស់។

☐ Allergy & Anaphylaxis Australia (**ប្រតិកម្មអាល្លើជី និងប្រតិកម្មអាណាហ្វីឡាក់ស៊ីសនៃប្រទេសអូស្ត្រាលី**) www.allergyfacts.org.au
អង្គភាពទ្រទ្រង់អ្នកជំងឺថ្នាក់ជាតិ ដែលផ្តល់ឱវាទ និងធនធានអំពីប្រតិកម្មអាល្លើជី និងប្រតិកម្មអាណាហ្វីឡាក់ស៊ីស។

☐ Food Standards Australia and New Zealand (FSANZ) (ស្តង់ដារចំណីអាហារនៃប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់) **(FSANZ)** **www.foodstandards.org.au**
ផ្តល់ព័ត៌មានអំពីច្បាប់នៃការបិទស្លាកចំណីអាហារ និងអំពីចំណីអាហារដែលមានសារជាតិដែលធ្វើឱ្យមានប្រតិកម្ម នៅលើស្លាកបិតចំណីអាហារ។

Translated by the WSLHD Translation Service June 2018 **Khmer**